ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ៧៥..សសរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតការិយាល័យសន្តិសុខថ្នាក់ខេត្ត-ក្រុង ប្រចាំនៅខេត្តបន្ទាយមានជ័យ

## ការិយាល័យសន្តិសុខថ្នាក់កណ្តាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញសេចក្តីសំរេចលេខ ៥៥សសរ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០២ ស្តីពីការបង្កើតគណៈបញ្ជាការការពារការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៣
- ផ្អែកតាមការចាំបាច់របស់ការិយាល័យសន្តិសុខថ្នាក់កណ្តាល

## សំរេច

**ប្រការ១** : ត្រូវបានបង្កើតការិយាល័យសន្តិសុខថ្នាក់ខេត្ត ប្រចាំនៅខេត្តបន្ទាយមានជ័យ ដែលមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | ថាច់ ឃន | អភិបាលខេត្ត | ប្រធាន |
| ២-ឯកឧត្តម | អន ស៊ី | អភិបាលរងទី ១ ខេត្ត | អនុប្រធាន |
| ៣-លោកឧត្តមសេនីយ៍ត្រី | គួយ ដោក | មេបញ្ជាការយោធភូមិភាគទី ៥ ប្រចាំទិសបន្ទាយមានជ័យ | អនុប្រធាន |
| ៤-លោកឧត្តមសេនីយ៍ត្រី | សូរ ចាន់ហេង | មេបញ្ជាការកងពលតូចលេខ ៥១ | សមាជិក |
| ៥-លោកវរៈសេនីយ៍ឯក | សុខ សារ៉េត | ស្នងការនគរបាលខេត្ត | សមាជិក |
| ៦-លោកវរៈសេនីយ៍ឯក | យ៉ាល់ សុទ្ធឡី | មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្ត | សមាជិក |
| ៧-លោកវរៈសេនីយ៍ឯក | រ័ត្ន ស្រ៊ាង | មេបញ្ជាការកងរាជអាវុធហត្ថខេត្ត | សមាជិក |
| ៨-លោក | ជង់ ប្រស៊ើដ្ឋ | នាយខុទ្ទកាល័យស្តីទីសាលាខេត្ត | សមាជិក |
| ៩-លោកវរៈសេនីយ៍ទោ | ពៅ ស៊ីជន | ស្នងការរងទី ១ នគរបាលខេត្ត | សមាជិក |
| ១០-លោកវរៈសេនីយ៍ទោ | សាយ សុវណ្ណារេត | មេបញ្ជាការកងព្រំដែន ៩០៣ | សមាជិក |
| ១១-លោក | ឈិម គ្រីហួង | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត | សមាជិក |
| ១២-លោក | យុត ស៊ីនី | ប្រធានរតនាគារខេត្ត | សមាជិក |
| ១៣-លោក | ឈុំ វណ្ណារិទ្ធ | ប្រធានមន្ទីរសុខាភិបាលខេត្ត | សមាជិក |
| ១៤-លោក | សាំង សាវ៉ាត | ប្រធានមន្ទីរសាធារណៈការនិងដឹកជញ្ជូន | សមាជិក |
| ១៦-លោក | អោក ប៊ុរ៉ា | ប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត | សមាជិក |
| ១៦-លោក | ពិន ខុនញ៉ា | ប្រធានមន្ទីរអប់រំខេត្ត | សមាជិក |

**ប្រការ២ :** ការិយាល័យសន្តិសុខថ្នាក់ខេត្តមានភារកិច្ច :

-ផ្សព្វផ្សាយ និងចាត់តាំងអនុវត្តផែនការលេខ ០១ផក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៣ ស្តីពីផែនការការពារសន្តិសុខ សុវត្ថិភាពក្នុងដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៣ របស់ការិយាល័យសន្តិសុខថ្នាក់កណ្តាល ។

-រៀបចំបង្កើតការិយាល័យសន្តិសុខថ្នាក់ខ័ណ្ឌស្រុក ឃុំសង្កាត់ តាមសេចក្តីសំរេចលេខ ០១សណារ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៣ របស់ការិយាល័យសន្តិសុខថ្នាក់កណ្តាល ។

-ទទួលគោលការណ៍ ផែនការផ្សេងៗពីការិយាល័យសន្តិសុខថ្នាក់កណ្តាល និងផ្សព្វផ្សាយដល់ការិយាល័យសន្តិសុខថ្នាក់ខ័ណ្ឌស្រុក ឃុំសង្កាត់ ព្រមទាំងណែនាំចាត់តាំងអនុវត្តឱ្យមានប្រសិទ្ធិភាព ។

-រៀបចំចាត់ចែង និងប្រើប្រាស់កម្លាំងគ្រប់ប្រភេទតាមផែនការកំណត់ និងណែនាំឱ្យកម្លាំងទាំងនោះអនុវត្តបានត្រឹមត្រូវ តាមបទបញ្ជា នីតិវិធីរបស់គ.ជ.ប និងច្បាប់បោះឆ្នោត ។

-ចាត់ចែងប្រើប្រាស់មធ្យោបាយ ឧបករណ៍សំភារៈរបស់បណ្តាអង្គភាពដែលមានស្រាប់ដើម្បីបំរើដល់កិច្ចការពារសន្តិសុខ សណ្តាប់ធ្នាប់សម្រាប់ការបោះឆ្នោត ។

-ប្រមូលផ្តុំព័ត៌មាន និងសភាពការណ៍ផ្សេងៗពីការិយាល័យសន្តិសុខថ្នាក់ក្រោម បូកសរុបរាយការណ៍ផ្ញើជូនមកការិយាល័យសន្តិសុខថ្នាក់កណ្តាលឱ្យបានទាន់ពេលវេលា ។

-ពិនិត្យដោះស្រាយពាក្យបណ្តឹង ឬឧប្បត្តិហេតុផ្សេងៗពាក់ព័ន្ធដល់សន្តិសុខនៃការបោះឆ្នោតដែលកើតឡើងក្នុងរង្វង់ភូមិសាស្ត្ររបស់ខ្លួន និងធ្វើរបាយការណ៍ជូនមកកាន់ការិយាល័យសន្តិសុខថ្នាក់កណ្តាលរៀងរាល់ ១៥ថ្ងៃម្តង ។ ករណីចាំបាច់ត្រូវរាយការណ៍ជាបន្ទាន់មកការិយាល័យសន្តិសុខថ្នាក់កណ្តាល ។

-ធ្វើគំរោងថវិកា ឧបករណ៍សំភារៈ មធ្យោបាយដឹកជញ្ជូន គ្រប់ប្រភេទបំរើការងារបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រសំរាប់មណ្ឌលបន្ទាយមានជ័យ ដាក់ជូនការិយាល័យសន្តិសុខថ្នាក់កណ្តាលពិនិត្យសំរេច ។

-ធ្វើរបាយការណ៍ចំណូលចំណាយថវិកា និងការប្រើប្រាស់ឧបករណ៍សំភារៈ មធ្យោបាយលើមូលដ្ឋាននៃគំរោងដែលការិយាល័យសន្តិសុខថ្នាក់កណ្តាលបានធ្វើការបែងចែកដល់ការិយាល័យសន្តិសុខគ្រប់ថ្នាក់ និងកងកម្លាំងទាំងអស់ ។

**ប្រការ ៣ :** ការិយាល័យសន្តិសុខថ្នាក់ខេត្តមានសិទ្ធិប្រើប្រាស់ត្រារបស់សាលាខេត្តបន្ទាយមានជ័យ និងមានសិទ្ធិបង្កើតក្រុមជំនួយការអចិន្ត្រៃយ៍ដើម្បីជាជំនួយក្នុងការតាមដានគ្រប់សភាពការណ៍ និងជួយដឹកនាំបញ្ជាតាមការណែនាំរបស់ប្រធានការិយាល័យសន្តិសុខថ្នាក់កណ្តាល ។

**ប្រការ ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការដ្ឋាននគរបាលជាតិ ប្រធានលេខាធិការដ្ឋាន ការិយាល័យសន្តិសុខថ្នាក់កណ្តាល មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស គណៈបញ្ជាការឯកភាពខេត្តបន្ទាយមានជ័យ និងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៣

**ឧបនាយករដ្ឋមន្ត្រី**

**និងជាប្រធានការិយាល័យសន្តិសុខថ្នាក់កណ្តាល**

**ស ខេង**

**កន្លែងទទួល:**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី ស ខេង
-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
-លេខាធិការដ្ឋានការិយាល័យសន្តិសុខថ្នាក់កណ្តាល
-ដូចប្រការ ៤
-សាលាខេត្តបន្ទាយមានជ័យ
-ឯកសារ-កាលប្បវត្តិ